# Judicial Notice (JN)

JN ជាវិធាននៃភស្តុតាង ដែលអនុញ្ញាតឲ្យចៅក្រមទទួលស្គាល់ជាផ្លូវការនូវអង្គហេតុមួយចំនួន ដូចជាឯកសារ ឬសក្ខីកម្មរបស់សាក្សី ថាពិត ដោយមិនចាំបាច់បង្ហាញភស្តុតាងជាផ្លូវការ ។

JN អាចពាក់ព័ន្ធអង្គហេតុគេដឹងជាទូទៅ (common knowledge) ឬអង្គហេតុដែលត្រូវបានសម្រេចហើយ (adjudicated facts) ដោយតុលាការដែលកំពុងវិនិច្ឆ័យសេចក្តីក្នុងរឿងក្នុងដៃ ឬតុលាការផ្សេង។ JN ប្រភេទទី១ ជាកាតព្វកិច្ចដែលត្រូវធ្វើ ក៏ប៉ុន្តែប្រភេទទី២ ជាឆន្ទានុសិទ្ធិរបស់ចៅក្រម (discretion)។ JN អាចពាក់ព័ន្ធទាំងអង្គហេតុនិងច្បាប់ ដែលគួរមានការឯកភាពតាំងពី ដំណាក់កាលដំបូងនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ រវាងរដ្ឋអាជ្ញានិងជនត្រូវចោទ។ ទោះបីជាយ៉ាងនេះក្តី JN ក៏អាចត្រូវបានធ្វើក្នុងអំឡុងពេលសវនាការផងដែរ។

គោលបំណងនៃ JN គឺដើម្បីសន្សំសំចៃតុលាការ (judicial economy) ធានាបាននូវសវនាការឲ្យបានឆាប់រហ័ស (right to reasonable time trial) ឬធានានូវផលប្រយោជន៍យុត្តិធម៌ (interest of justice)។ នេះដោយសារ គេសន្មតិថា អង្គហេតុមានភាពពិតប្រាកដ ឬបានឯកភាពរួចហើយ (agreed facts) មិនចាំបាច់ចំណាយពេលពិភាក្សាឬបង្ហាញទៀត។ ទោះបីជាយ៉ាងនេះក្តី អង្គហេតុនេះ មិនត្រូវពាក់ព័ន្ធដល់ការសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ បន្ថែមពីលើនេះ ការអនុវត្ត JN ត្រូវថ្លឹងថ្លែងជាមួយនូវសិទ្ធិរបស់ជនត្រូវចោទ។ ក្នុងន័យថា រដ្ឋអាជ្ញាអាចរួចពីបន្ទុកភស្តុតាងមួយចំនួន ក៏ប៉ុន្តែប្រសិនបើជនត្រូវចោទតវ៉ា រដ្ឋអាជ្ញាត្រូវបង្ហាញភស្តុតាងផ្ទុយ។

JN មានប្រភពពីប្រព័ន្ធយុត្តិធម៌នៃប្រព័ន្ធច្បាប់កំមុនឡ (adversary proceeding) ទោះបីជាយ៉ាងនេះក្តី ដោយសារវាមានអត្ថប្រយោជន៍ ប្រព័ន្ធស៊ើបអង្កេត (inquiry proceeding) នៃប្រព័ន្ធស៊ីវិលឡដូចជាកម្ពុជា គួរយកមកសិក្សានិងអនុវត្ត។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ក៏ប្រើប្រាស់អង្គហេតុឯកភាព (agreed facts) រវាងជនជាប់ចោទនិងសហព្រះរាជអាជ្ញាផងដែរ។